00618822

០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក F12/1

ឯកសារបានទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 28 / 10 / 2010
ម៉ោង (Time/Heure): 10:20
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Ratanak

**នៅចំពោះមុខ អង្គជំនុំជម្រះតុលាការកំពូល**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**

## ព័ត៌មានពិស្តារអំពីការដាក់ឯកសារ

សំណុំរឿងលេខ: ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ត.ក
កាលបរិច្ឆេទឯកសារ: ២៨ តុលា ឆ្នាំ២០១០
ភាគីដាក់ឯកសារ: សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម១
ដាក់ជូន: អង្គជំនុំជម្រះតុលាការកំពូល
ភាសាដើម: អង់គ្លេស

## ចំណាត់ថ្នាក់ឯកសារ

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ៖ សាធារណៈ
ចំណាត់ថ្នាក់ឯកសារដោយ កសចស
ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្តោះអាសន្ន៖
ឈ្មោះមន្ត្រីកត់ត្រា៖
ហត្ថលេខា៖

---

# សារណាបន្ថែមរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី ក្រុម១ ចំពោះសេចក្តីជូនដំណឹងអំពីគោលបំណង

---

<u>ដាក់ដោយ</u>៖

**សហមេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក Karim A. A. Khan
លោកស្រី ទី ស្រ៊ីនណា
លោក Alain WERNER
លោកស្រី Brianne McGONIGLE

<u>ដោយមានជំនួយពី</u>៖

លោកស្រី Daniella RUDY
លោក Kate GIBSON

<u>ផ្ញើជូន</u>៖

**អង្គជំនុំជម្រះតុលាការកំពូល៖**

ចៅក្រម គង់ ស្រ៊ឹម
ចៅក្រម Motoo Noguchi
ចៅក្រម សោម សេរីវុឌ្ឍន៍
ចៅក្រម Agniezska KLONOWIECKAMILART
ចៅក្រម ស៊ិន វិទ្ធិ
ចៅក្រម Chandra Nihal Jayasinghe

00618823



**ចម្លងជូន៖**

**ជនជាប់ចោទ៖**

លោក កាំង ហ្គេកអ៊ាវ ហៅ "ឌុច"

**សហមេធាវីការពារក្ដីជនជាប់ចោទ៖**

លោក ការ សាវុត្ថ

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោកស្រី ជា លាង

លោក Andrew T. CAYLEY

លោក យ៉េត ចរិយា

លោក William SMITH

លោក ពេជ្រ សម្បត្តិ

**មេធាវីតំណាងភាគីដើមបណ្ដឹងរដ្ឋប្បវេណី៖**

លោក គឹម ម៉េងឃី

លោកស្រី ម៉ុច សុវណ្ណារី

លោកស្រី Martine JACQUIN

លោកPhillipe CANONNE

លោក គង់ ពិសី

លោក ហុង គឹមសួន

លោក យុង ផានិត

លោកស្រី Silke STUDZINSKY

លោក Pierre-Oliver SUR

## សេចក្តីផ្តើម

១. កាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ បានដាក់នូវបណ្តឹងសារទុក្ខភ្លាមៗ[1] ដោយយោងទៅតាមវិធានផ្ទៃក្នុង ១០៤(៤) (វិសោធនកម្មលើកទី៣) តំណាងឱ្យដើមបណ្តឹងរដ្ឋប្បវេណីក្នុងក្រុម១ ចំនួន៩នាក់។ នៅថ្ងៃទី៣១ ខែសីហា ឆ្នាំ២០១០ ក្រឡាបញ្ជីអង្គជំនុំជម្រះតុលាការកំពូលបានណែនាំសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ឱ្យដាក់បណ្តឹងសារទុក្ខសាជាថ្មី ដោយមានភ្ជាប់បន្ថែមជាមួយនូវលិខិតប្រគល់សិទ្ធិដោយអណត្តិរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំង៩នាក់នោះ។ ក្រោយមក សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ បានដាក់បណ្តឹងសារទុក្ខភ្លាមៗសាជាថ្មី នៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១០ ដោយមានភ្ជាប់មកជាមួយនូវលិខិតប្រគល់សិទ្ធិដោយអណត្តិដូចលើកឡើងខាងលើ។

២. នៅថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១០ អង្គជំនុំជម្រះតុលាការកំពូល (អ.ជ.ត.ក) បានចេញសេចក្តីសម្រេចទៅលើចរិតលក្ខណៈរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ដែលសេចក្តីសម្រេចនេះមានចំណងជើងថា សេចក្តីសម្រេចអំពីឋានៈដើមបណ្តឹងរដ្ឋប្បវេណីនៃបណ្តឹងសារទុក្ខភ្លាមៗរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ នៅក្នុងសាលក្រមអង្គជំនុំជម្រះសាលាដំបូង។[2] នៅក្នុងសេចក្តីសម្រេចនោះ អ.ជ.ត.ក យល់ឃើញ ដោយហេតុថាអង្គជំនុំជម្រះសាលាដំបូង បានបដិសេធដើមបណ្តឹងរដ្ឋប្បវេណីទាំង៩ ដោយសារតែអង្គសេចក្តីនៃពាក្យសុំធ្វើដើមរបស់ដើមបណ្តឹងរដ្ឋប្បវេណីរបស់ពួកគេ[3] អ.ជ.ត.ក ចាត់ទុកថា "ទ្រឹស្តីនៃការប្រើប្រាស់ "បណ្តឹងសារទុក្ខភ្លាមៗ" មិនអាចយកមកអនុវត្តនៅក្នុងករណីធ្វើបណ្តឹងសារទុក្ខជំទាស់ទៅនឹងសេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង ដែលបដិសេធមិនទទួលស្គាល់ពាក្យសុំធ្វើដើមបណ្តឹងរដ្ឋប្បវេណីទាំង៩នោះទេ"។[4] ប៉ុន្តែ សេចក្តីសម្រេចបដិសេធមិនទទួលស្គាល់ពាក្យសុំធ្វើដើមបណ្តឹងរដ្ឋប្បវេណីចំនួន៩នោះស្ថិតនៅក្នុង "របបនីតិវិធីប្រើប្រាស់ចំពោះបណ្តឹងសារទុក្ខជំទាស់ទៅនឹងសាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូង"។ [5]

៣. បើទោះបីជាមានសេចក្តីសម្រេចបដិសេធមូលដ្ឋាននីតិវិធីដែលបណ្តឹងសារទុក្ខភ្លាមៗរបស់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១បានផ្អែកលើក៏ដោយ ក៏អ.ជ.ត.ក សម្រេចថា "ដើម្បី

---

[1] E188/10

[2] F811

[3] អង្គជំនំជម្រះសាលាដំបូង កថាខណ្ឌ ៦៣៦, ៦៤៧-៦៤៩ ។

[4] F811 កថាខណ្ឌ ៥។

[5] សូមមើល F811 កថាខណ្ឌ ៤ ។

ភាពយុត្តិធម៌ និងបើពិនិត្យមើលអំពីក្របខណ្ឌមិនធម្មតា និងស្មុគស្មាញនៃការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខអ.វ.ត.ក" អ.ជ.ត.ក នឹងចាត់ទុកបណ្តឹងសារទុក្ខភ្លាមៗជាសេចក្តីជូនដំណឹងអំពីការធ្វើបណ្តឹងសារទុក្ខ និងជាសេចក្តីសង្ខេបបណ្តឹងសារទុក្ខ។[6] ដើម្បីជាផលប្រយោជន៍ល្អបំផុតរបស់ដើមបណ្តឹងរដ្ឋប្បវេណីទាំង៩នាក់នោះ អ.ជ.ត.ក បានសម្រេចផ្តល់ឱកាសដល់សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ ដើម្បីអាចដាក់បន្ថែមនូវ "សេចក្តីជូនដំណឹងបន្ថែមអំពីបណ្តឹងសារទុក្ខ និងសេចក្តីសង្ខេបបណ្តឹងសារទុក្ខបន្ថែមទាក់ទងនឹងផលប្រយោជន៍រដ្ឋប្បវេណីផ្សេងទៀតនៃបុគ្គលជាដើមបណ្តឹងរដ្ឋប្បវេណីទាំង៩នាក់"។[7]

---

[6] សូមមើល F811 កថាខ័ណ្ឌ ៥។

[7] សូមមើល F811 កថាខ័ណ្ឌ ៦។

00618826



F12

## សេចក្តីជូនដំណឹងអំពីគោលបំណង

៤. តាមរយៈសេចក្តីជូនដំណឹងនេះ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១សូមទទួលយកនូវសេចក្តីសម្រេចចេញដោយអង្គជំនុំជម្រះតុលាការកំពូលនៅថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០១០។ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ អ.ជ.ត.ក ដែលបានប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ខ្លួន ចាត់ទុកបណ្តឹងសារទុក្ខភ្លាមៗជាសេចក្តីជូនដំណឹងអំពីបណ្តឹងសារទុក្ខ និងជាបណ្តឹងសារទុក្ខ នៅក្រោមរបបនីតិវិធីទាក់ទងទៅនឹងសាលក្រមអង្គជំនុំជម្រះសាលាដំបូង។ បើទោះបីជាមានឱកាសក្នុងការដាក់បន្ថែមនូវសេចក្តីជូនដំណឹងបន្ថែមពីបណ្តឹងសារទុក្ខ និងសេចក្តីសង្ខេបបណ្តឹងសារទុក្ខបន្ថែមក៏ដោយ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ សូមបញ្ជាក់ជូនអង្គជំនុំជម្រះតុលាការកំពូលថា សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ មិនមានបំណងដាក់សារណាសង្ខេបបន្ថែម ឬ ពង្រីកបញ្ហា ដោយមានដាក់បន្ថែមនូវបញ្ហាសំណងជំងឺចិត្តនោះទេ។

៥. សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ សូមបញ្ជាក់ដោយក្តីគោរពថា សិទ្ធិទទួលស្គាល់និងការសម្រេចលើឋានៈសមរម្យជាដើមបណ្តឹងរដ្ឋប្បវេណីដែលទទួលស្គាល់ជាទូទៅនោះ កើតឡើងមុនការពិចារណាទៅលើអ្វីដែលស្មើនឹងសំណងជំងឺចិត្តសមរម្យ (ឬដែលមាន) ទាក់ទងទៅនឹងអង្គហេតុនៅក្នុងសំណុំរឿង។ ពិតណាស់ បើទោះបីជាមានដីការរបស់អង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យចងក្រង និង ដាក់នៅលើគេហទំព័ររបស់ អ.វ.ត.ក នូវពាក្យសម្តីរបស់ ឌុច សម្តែងការសោកស្តាយ ឬ វិប្បដិសារី ឬការទទួលខុសត្រូវចំពោះអ្វីដែលបានកើតឡើងនៅស-២១[8] វាច្បាស់ណាស់ថា សំណងជំងឺចិត្តសំខាន់សម្រេចដោយអង្គជំនុំជម្រះសាលដំបូងនោះ គឺការទទួលស្គាល់ឋានៈជាដើមបណ្តឹងរដ្ឋប្បវេណី។ នេះគឺជាភ័ស្តុតាងមួយក្នុងចំណោមភ័ស្តុតាងផ្សេងៗដែលអង្គជំនុំជម្រះសាលាដំបូងបង្គាប់ឱ្យដាក់ឈ្មោះរបស់ដើមបណ្តឹងរដ្ឋប្បវេណី ដែលត្រូវបានទទួលស្គាល់ទាំងអស់នៅក្នុងសាលក្រម។[9] ហេតុដូច្នេះ សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១ រក្សាគោលជំហរដដែលដូចមាននៅក្នុងសារណាអំពីសាលក្រមអង្គជំនុំជម្រះសាលាដំបូង អំពីអង្គសេចក្តីនៃពាក្យសុំធ្វើដើមបណ្តឹងរដ្ឋប្បវេណី និងស្វែងរកការទទួលស្គាល់ពាក្យសុំធ្វើដើមបណ្តឹង

---

[8] សាលក្រមអង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៦៨។

[9] សូមមើលសាលក្រមអង្គជំនុំជម្រះសាលាដំបូង កថាខណ្ឌ ៦៦៧។

00618827

001/18-07-2007-អ.វ.ត.ក/អ.ជ.ត.ក

P12

រដ្ឋប្បវេណីទាំង៩ ដោយផ្អែកទៅលើមូលហេតុ ដូចមាននៅក្នុងសារណាដាក់ជូនកាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០១០ ជាទម្រង់នៃសំណងជំងឺចិត្ត។

សូមអង្គជំនុំជម្រះតុលាការកំពូលទទួលយកសារណាបន្ថែមដោយក្តីគោរព
សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណីក្រុម១
ចុះហត្ថលេខាថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១០

Karim A. A. Khan ទី ស្រ៊ីនណា Alain Werner

Brianne McGonigle Daniella Rudy Kate Gibson